00201806

A189/I/14

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១០)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ១០ កក្កដា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 07 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីដែលស្នើសុំការកំណត់ពេលវេលា ជាបន្ទាន់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍អំពីការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ**

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

PRE-TRIAL CHAMBER · CHAMBRE PRELIMINAIRE · E.C.C.C.

00201807



១- **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក") បានទទួល "បណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត នូវសំណើសុំឲ្យអ្នកជំនាញផ្នែកចិត្តសាស្ត្រពិនិត្យ **អៀង សារី** ដែលបានដាក់នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០០៨ ដើម្បីសម្រេចថាជននេះមានសុខភាពល្អគ្រប់គ្រាន់អាចចូលរួមក្នុងការជំនុំជម្រះក្តី ("បណ្តឹងឧទ្ធរណ៍") ដោយសហមេធាវីការពារក្តីស្នើសុំឲ្យអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ឲ្យសហព្រះរាជអាជ្ញា ដាក់សេចក្តីសន្និដ្ឋានតបក្នុងរយៈពេលបីថ្ងៃចាប់ពីថ្ងៃជូនដំណឹងបណ្តឹងឧទ្ធរណ៍នេះ។

២- ស្របតាមសេចក្តីណែនាំចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ របស់អង្គបុរេជំនុំជម្រះ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទាក់ទងនឹងការកំណត់ពេលវេលាជាបន្ទាន់សម្រាប់ការដាក់សារណា ("សេចក្តីសន្និដ្ឋានតប")។អង្គបុរេជំនុំជម្រះពុំបានទទួលសារណាតបពីដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

៣- វិធាន ៣៩-២ នៃវិធានផ្ទៃក្នុងចែងថា អង្គបុរេជំនុំជម្រះអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ។

៤- សហមេធាវីការពារក្តីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះថា កាលពីថ្មីៗនេះ សហព្រះរាជអាជ្ញាបានដោះស្រាយបញ្ហាយ៉ាងស្រដៀងគ្នា នៅក្នុងរឿងក្តីខុសគ្នា ហើយពុំបានជំទាស់ទៅនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រឡើយ។

៥- នៅក្នុងសេចក្តីសន្និដ្ឋានតប សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គហេតុនៅក្នុងរឿងក្តីនេះមានលក្ខណៈខុសគ្នា មានការលើកឡើងនូវចំណុចច្បាប់ថ្មី ភាគីផ្សេងទៀតត្រូវឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ ហើយសហមេធាវីការពារក្តីពុំបានលើកមកបង្ហាញថា តើហេតុអ្វីបានបញ្ហានេះតម្រូវឲ្យមានភាពជាបន្ទាន់នោះទេ។

៦- ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំចាំបាច់តម្រូវឲ្យមានការកំណត់ពេលវេលាជាបន្ទាន់ឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា:**

*ការឆ្លើយតបណាមួយរបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី គួរតែដាក់ស្របតាមការកំណត់ពេលវេលាដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក។*

ភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**